# សេចក្តីថ្លែងការរួមរបស់សហគមន៍ការពារទន្លេសេសាន ស្រែពក សេកុង
# ក្នុងឱកាសពិធីប្រារព្ធបុណ្យខួបបណ្តាញការពារទន្លេបី
# នាថ្ងៃទី១០-១១ ខែមិថុនា ឆ្នាំ២០០៨ ស្រុកបានលុង ខេត្តរតនគីរី
# ទាក់ទងនឹងផែនការសង់ទំនប់វារីអគ្គិសនីសេសានក្រោម២ ក្នុងប្រទេសកម្ពុជា

.........................................

## គោរពជូន
## រាជរដ្ឋាភិបាលកម្ពុជា

យើងខ្ញុំជាតំណាងសហគមន៍ដែលមានចំនួនជាង២០០នាក់មកពីតំបន់ទន្លេសេសាន ស្រែពក និងសេកុង ដែលកន្លងមកធ្លាប់បានជួបប្រទះនូវផលលំបាក និងការប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយសារការសង់ទំនប់វារីអគ្គិសនីក្នុងប្រទេសវៀតណាម។ ថ្ងៃនេះយើងបានមកជួបជុំគ្នាដើម្បីសំដែងនូវក្តីព្រួយបារម្មណ៍ និងសូមស្នើដល់រាជរដ្ឋាភិបាលកម្ពុជាអោយពិចារណានូវចំណុចដូចខាងក្រោម ដែលទាក់ទងទៅនឹងផែនការសង់ទំនប់វារីអគ្គិសនី សេសានក្រោម២ ។

**យើងខ្ញុំយល់ថាបើសិនជាទំនប់សេសានក្រោម២ត្រូវបានសាងសង់មែននោះ វានឹងប៉ះពាល់ដូចខាងក្រោមៈ**

- ប៉ះពាល់ និងបាត់បង់ធនធានធម្មជាតិតាមដងទន្លេ ដូចជា បន្លែធម្មជាតិ ពូជត្រី និងពពួកសត្វដែលរស់នៅពឹងអាស្រ័យនិងទន្លេ
- ខូចខាតដល់ហេដារចនាសម្ពន្ធ័សង្គម ដូចជា សាលារៀន ផ្លូវថ្នល់ វត្តអារាម មណ្ឌលសុខភាព ។ល។
- លិចលង់ និងបាត់បង់ផ្ទៃដីសំរាប់ដំណាំកសិកម្ម
- ប៉ះពាល់គុណភាពទឹក និងខ្វះទឹកស្អាតប្រើប្រាស់
- លំហូរទឹកនិងមានការប្រែប្រួល ឡើងចុះ មិនទៀតទាត់ ដែលធ្វើអោយរំខានដល់ការប្រកបមុខ របរចិញ្ចឹមជីវិតរបស់ប្រជាជន
- បាត់បង់ប្រាក់ចំណូលរបស់ប្រជាពលរដ្ឋនៅតាមដងទន្លេ ដែលប្រជាជនភាគច្រើនពឹងផ្អែកលើការនេសាទត្រី
- ប៉ះពាល់ដល់ចរាចរឡើងចុះរបស់ត្រី ហើយពូជត្រីនិងត្រូវបាត់បង់
- ប៉ះពាល់ដល់ទំនៀមទម្លាប់ប្រពៃណីរបស់ប្រជាជាន និងរំខានដល់ការសិក្សារបស់កុមារ
- មានក្តីបារម្ភចំពោះការផ្តល់សំណងមិនបានសមស្រប និងបារម្ភពីនិរន្តរភាពនៃជីវភាពរស់នៅ នៅពេលដែលភូមិដ្ឋានត្រូវបានជន្លៀសទៅកន្លែងថ្មី។

**ដោយមានការព្រួយបារម្ភដូចខាងលើនេះ បើសិនជាទំនប់សេសានក្រោម២ ត្រូវបានសង់មែននោះ យើងខ្ញុំសូមសំណូមពរដល់រាជរដ្ឋាភិបាលដូចខាងក្រោមៈ**

- ស្នើសុំអោយរដ្ឋាភិបាលជួយផ្តល់សំណងដល់សហគមន៏ដែលរងគ្រោះ នូវចំនួនដីស្រែ ចំការ លំនៅដ្ឋាន ផលដំណាំ ឱ្យបានសមស្រប និងអាចទទួលយកបាន
- សូមស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធសង្គមដែលខូចខាត និងធានាអោយមាននិរន្តរភាពក្នុងការរស់នៅរបស់ប្រជាជន
- សូមផ្តល់នូវដំណោះស្រាយចំពោះកិច្ចការពារធនធានត្រី ធ្វើយ៉ាងណាកុំអោយមានការរាំងខ្ទប់ដល់ចរាចររបស់ត្រីឡើងចុះ
- សូមឱ្យស្ថាប័នរាជរដ្ឋាភិបាលពាក់ព័ន្ធធ្វើការសហការជាមួយសហគមន៏ អាជ្ញាធរមូលដ្ឋាន សង្គមស៊ីវិល មុននឹងធ្វើសេចក្តីសម្រេចចិត្តសង់ទំនប់
- សូមស្នើអោយមានការពិភាក្សា និងសិក្សាផ្ទាល់ជាមួយប្រជាពលរដ្ឋអោយបានលំអិត និងមានការឯកភាពជាមុន ទាក់ទងនិងការផ្តល់សំណង
- បង្កើតលក្ខន្តិកៈ និងគោលការណ៏យបានច្បាស់លាស់សម្រាប់ផ្តល់សំណងឱ្យសមស្រប និងយុត្តិធម៌ចំពោះការបាត់បង់ទ្រព្យសម្បត្តិ មុខរបរចិញ្ចឹមជីវិត បរិស្ថាន និងសង្គម
- សូមឱ្យរដ្ឋាភិបាលផ្តល់អគ្គិសនីប្រើប្រាស់ដល់សហគមន៏ ដែលរងគ្រោះដោយមិនគិតថ្លៃ
- សូមអោយសងនូវការបាត់បង់ប្រាក់ចំណូលជាប្រចាំថ្ងៃពីការនេសាទត្រី
- ធានានូវសុវត្ថិភាព និងអាយុជីវិតរបស់ប្រជាជនក្នុងករណីមានបញ្ហាកើតឡើងដោយសង់ទំនប់ សេសាន ២ នេះ ។

យើងខ្ញុំសង្ឃឹមថា រាល់បញ្ហានិងក្តីប្រារម្ភដែលបានលើកឡើងខាងលើនេះ រាជរដ្ឋាភិបាលកម្ពុជា និងភាគីពាក់ព័ន្ធទាំងអស់ និងយកទៅពិចារណា នឹងធ្វើការដោះស្រាយជូនដល់យើងខ្ញុំដោយសមស្រប ។

ថ្ងៃទី១១ ខែមិថុនា ឆ្នាំ ២០០៨

**តំណាងសហគមន៍ទន្លេ**

**សេសាន ស្រែពក សេកុង**